រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

032KH01A-01

ការចែកចាយដំណឹងល្អប្រាប់អ្នកដទៃ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

៣២

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

គោលការណ៍ព្រះគម្ពីរត្រាំពីរយ៉ាង
សំរាប់ផ្សាយដំណឹងល្អអំពីព្រះគ្រីស្ត

ផ្សាយដំណឹងល្អថ្វាយព្រះគ្រីស្ត :

១- រួមជាមួយពួកអ្នកជឿឯទៀត ។

២- ដំបូង ផ្សាយដំណឹងល្អប្រាប់មិត្តភក្តិ និងសាច់ញាតិជាមុនសិន ។

៣- ដោយជំនឿ ។

៤- ដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។

៥- ដោយរៀបរាប់អំពីព្រះអង្គច្រើនជាងគេ ។

៦- ដោយសេចក្តីស្រឡាញ់ ។

៧- ដើម្បីបង្កើតសាវ័កស្មោះត្រង់របស់ព្រះគ្រីស្ត ។

កំណត់ចំណាំ

© Project WorldReach © SEAN

កំណត់ចំណាំ

ផ្សាយដំណឹងល្អដល់មនុស្ស រួមជាមួយពួកអ្នកជឿឯទៀត

ផ្សាយដំណឹងល្អ បានន័យថា និយាយប្រាប់អ្នកឯទៀតអំពីជីវិត ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអម្ចាស់យេស៊ូ គ្រីស្ត ។ សេចក្តីបង្គាប់មួយរបស់ព្រះគ្រីស្ត គឺផ្សាយដំណឹងល្អ ថ្វាយព្រះអង្គ ។ ហេតុនេះហើយបានជាយើងបង្រៀនពួកអ្នកជឿ ទាំងអស់អោយចេញទៅប្រកាសប្រាប់ដំណឹងល្អអំពីព្រះយេស៊ូដល់ មនុស្សឯទៀត (ម៉ាថាយ ២៨:១៩, កិច្ចការ ១:៨) ។

បើគ្រាន់តែបង្រៀនមេរៀន អំពីការផ្សាយដំណឹងល្អដល់មនុស្ស ឯទៀត មិនទាន់គ្រប់គ្រាន់ទេ ។ មនុស្សចេះផ្សាយដំណឹងល្អ ដោយសារគេចេញទៅអនុវត្ត ។ សូមនាំពួកសិស្សដែលអ្នក បង្រៀនទៅជាមួយអ្នក ដើម្បីនាំមិត្តភក្តិ និងបងប្អូនរបស់ពួកគេ ផ្ទាល់អោយថ្វាយខ្លួនទៅព្រះគ្រីស្ត (ម៉ាថាយ ៤:១៩) ។

នៅពេលដែលក្រុមជំនុំណាមួយលែងផ្សាយដំណឹងល្អ ក្រុមជំនុំ នោះនឹងនៅទ្រឹងលែងរីកចំរើនទៅមុខ ។ សភាពបែបនេះ កើត មានជារឿយៗចំពោះក្រុមជំនុំថ្មី ដែលទើបនឹងចាប់ផ្តើមមានការ ប្រជុំថ្វាយបង្គំ ជាទៀងទាត់ ។ សូមជំរុញអោយក្រុមជំនុំរបស់ អ្នកយកចិត្តទុកដាក់ផ្សាយដំណឹងល្អដល់មនុស្សឯទៀតជានិច្ច ។



ការផ្សាយដំណឹងល្អ ជាការងារប្រចាំថ្ងៃរបស់ :

☐ តែគ្រូគង្វាលប៉ុណ្ណោះ ។

☐ អ្នកជឿគ្រប់រូប ។

ព្រះអម្ចាស់យេស៊ូចាត់ពួកសាវ័ករបស់ព្រះអង្គពីរៗនាក់ អោយចេញទៅ (ម៉ាកុស ៦:៧) ។ ពួកសាវ័កមិនដែលចេញទៅម្នាក់ឯងទេ (លើកលែងតែក្នុងករណីពិសេសបំផុត) ។

កំណត់ចំណាំ

© Project WorldReach © SEAN

- សរសេរឈ្មោះមនុស្សយ៉ាងតិចបីនាក់ ដែលបានទទួលព្រះគ្រីស្ត ដោយសារអ្នកផ្សាយដំណឹងល្អដល់គេ ឬឈ្មោះរបស់មនុស្សពីរ ឬបីនាក់ ដែលទៅជាមួយអ្នក ដើម្បីផ្សាយដំណឹងល្អ :

- សរសេរគោលការណ៍ទាំងប្រាំពីរ សំរាប់ការផ្សាយដំណឹងល្អ ដែលមាននៅក្នុងមេរៀននេះ :

បើសិនជាយើងចេញទៅពីរៗនាក់ ឬ ជាក្រុមតូចៗ នោះអ្នកផ្សាយដំណឹងល្អ ដែលមានបទពិសោធន៍ច្រើន អាចបង្ហាញពួកអ្នកជឿដែលមិនទាន់មានបទពិសោធន៍ អំពីរបៀបផ្សាយដំណឹងល្អ ។ ការចេញទៅផ្សាយដំណឹងល្អមានគ្នាពីរៗនាក់ នាំឱ្យគេអាចជួយគ្នាទៅវិញទៅមក ។

បើសិនជាគ្មាននរណាទៅជាមួយអ្នកទេ អ្នកមិនត្រូវ ចូលទៅផ្ទះដែលមានមនុស្សភេទផ្ទុយពីអ្នក នៅតែម្នាក់ឯងទេ ។

ការដែលប្រសើរ គឺផ្សាយដំណឹងល្អ :

- ☐ តែឯង ។
- ☐ ជាមួយនរណាម្នាក់ទៀត ។

© Project WorldReach © SEAN

ដំបូង ផ្សាយដំណឹងល្អប្រាប់មិត្តភក្តិ និងសាច់ញាតិជាមុនសិន



- បង្រៀនពួកអ្នកជឿថ្មីអោយចេះអធិស្ឋានខ្លាំងក្លា ដើម្បីអោយពួកអ្នកឯទៀតជឿ និង ថ្វាយខ្លួន ហើយបង្រៀនគេអោយមានសេចក្តីស្រឡាញ់ចំពោះក្រុមគ្រួសារ និងមិត្តភក្តិរបស់គេ ។

- នាំពួកអ្នកជឿថ្មីទៅផ្សាយដំណឹងល្អជាមួយអ្នក ដើម្បីបង្ហាញពួកគេពីរបៀបផ្សាយដំណឹងល្អ (សូមប្រើកូនសៀវភៅទី ២ «ដំណឹងល្អបំផុត» ឬ កូនសៀវភៅទី ១៥ «ព្រះគ្រីស្តត្រាស់ហៅអ្នក» ឬ វិធីងាយស្រួលផ្សេងៗទៀត) ។

- ជូនពត៌មានប្រាប់ក្រុមជំនុំ ឬក្រុមរបស់អ្នកអំពីការខិតខំប្រឹងប្រែងយ៉ាងខ្លាំងរបស់អ្នកជឿ ដែលចេញទៅសួរសុខទុក្ខ និងផ្សាយដំណឹងល្អ ។ ធ្វើដូចនេះ គឺជំរុញទឹកចិត្តអ្នកឯទៀតអោយមានបំណងចូលរួមជាមួយអ្នកទាំងនោះ ។

- បើសិនជាចាំបាច់ សូមកំរិតចំនួនការប្រជុំប្រចាំសប្តាហ៍ដើម្បីអោយសមាជិកថ្មី មានពេលទៅផ្សាយដំណឹងល្អតាមផ្ទះ ។

© Project WorldReach © SEAN

១២- ក្រៅពីទទួលពិធីជ្រមុជទឹក អ្នកជឿថ្មីត្រូវរៀនប្រតិបត្តិតាមព្រះគ្រីស្ត ។ ដើម្បីអាចផ្សាយដំណឹងល្អប្រកបដោយប្រសិទ្ធិភាពបាន អ្នកជឿថ្មីត្រូវ :

- ☐ ចេញទៅផ្សាយដំណឹងល្អប្រាប់មិត្តភក្តិរបស់ខ្លួនភ្លាមៗ ។
- ☐ រង់ចាំនៅផ្ទះ រហូតដល់ពេលរៀនបានច្រើន ។

អ្នកជឿថ្មីដែលចង់ប្រតិបត្តិតាមព្រះគ្រីស្ត ត្រូវចាប់ផ្តើមផ្សាយដំណឹងល្អប្រាប់ក្រុមគ្រួសារ និង មិត្តភក្តិរបស់ខ្លួនភ្លាមៗ ។

កិច្ចការដែលត្រូវអនុវត្ត

- អាន និងរិះគិតពិចារណាអំពី កិច្ចការ ១៦:១១-៣៤ ។
- អធិស្ឋានសូមអោយសមាជិកគ្រប់រូបរបស់ក្រុមជំនុំរបស់អ្នកក្លាយជាអ្នកផ្សាយដំណឹងល្អអំពីព្រះអម្ចាស់យេស៊ូគ្រីស្តប្រកបដោយប្រសិទ្ធិភាព ។

នៅក្នុងសៀវភៅកិច្ចការ យើងឃើញថា មានក្រុមគ្រួសារជាច្រើនដែលបានទទួលជឿលើព្រះយេស៊ូ តាមរយៈសាច់ញាតិម្នាក់ ដែលផ្សាយដំណឹងល្អប្រាប់គេ (កិច្ចការ ១០:២៤-៤៤, ១៦:១៤-១៥, ១៦:៣០-៣៤, ១៨:៨) ។

យើងបង្កើតបានផលផ្លែច្រើន បើសិនជាជំបួងយើងផ្សាយដំណឹងល្អទៅ :

- ☐ ពួកអ្នកដែលមិនធ្លាប់ស្គាល់ ។
- ☐ មិត្តភក្តិ និង សាច់ញាតិ ។

ផ្សាយដំណឹងល្អ ដោយជំនឿ

កិច្ចការសង្គ្រោះរបស់ព្រះអម្ចាស់យេស៊ូធំធេងណាស់ គឺព្រះអង្គលើកលែងទោស និងទទួលទាំងមនុស្ស ដែលអាក្រក់បំផុតទៀតផង (១ ធីម៉ូថេ ១:១២-១៥) ។ យើងបានសង្គ្រោះ ដោយសារជំនឿរបស់យើងលើព្រះអម្ចាស់ ហើយយើងក៏នាំមនុស្សឯទៀតឱ្យបានសង្គ្រោះ ដោយសារជំនឿលើព្រះអម្ចាស់នេះដែរ (ម៉ាថាយ ៨:១៣) ។



ជំនឿរបស់យើង នាំអោយយើងអាចផ្សព្វផ្សាយដំណឹងល្អដល់ក្រុមគ្រួសាររបស់យើង (កិច្ចការ ១៦:៣១) ។ ព្រះជាម្ចាស់ជួយអ្នកជឿម្នាក់ៗអោយបង្កើនជំនឿរបស់ខ្លួន ។ ឯអ្នកដែលមិនទាន់ជឿវិញ នៅពេលដំបូង ជំនឿរបស់យើងសំខាន់ណាស់ក្នុងការនាំឱ្យអ្នកទាំងនោះសំរេចចិត្តទទួលជឿព្រះយេស៊ូ ។

- ☐ ព្រះយេស៊ូគ្រីស្ដ និងរបៀបដែលព្រះអង្គសង្គ្រោះយើង ។

១០- នៅពេលដែលយើងផ្សាយដំណឹងល្អ សេចក្តីសំខាន់បំផុត គឺយើងត្រូវពន្យល់អំពី :

- ☐ គោលលទ្ធិជ្រើសៗ ។
- ☐ ការសុគត ការមានព្រះជន្មរស់របស់ព្រះយេស៊ូ និងការដែលព្រះអង្គលើកលែងទោសយើងអោយរួចពីបាប ។

១១- ក្រោយដែលពួកសាវ័កបានពន្យល់ អំពីការសុគតរបស់ព្រះយេស៊ូ ដើម្បីសង្គ្រោះមនុស្សលោក ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ និងការដែលព្រះអង្គលើកលែងទោសមនុស្សរួចហើយ ពួកសាវ័កបញ្ជាក់ពីជំនឿថ្មីរបស់អស់អ្នកដែលទទួលដំណឹងល្អនោះ :

- ☐ ដោយធ្វើពិធីជ្រមុជទឹកអោយពួកគេ ។
- ☐ ដោយអញ្ជើញពួកគេមកខាងមុខក្នុងកម្មវិធីថ្វាយបង្គំ ។

© Project WorldReach © SEAN

៧- យោងទៅតាម ១ កូរិនថូស ២:៤-៥ ពេលយើងផ្សព្វ
ផ្សាយដំណឹងល្អ យើងត្រូវ :

☐ បន្ទាបខ្លួន និងពឹងផ្អែកលើឫទ្ធានុភាពរបស់ព្រះវិញ្ញាណ
ដ៏វិសុទ្ធ ។

☐ ពឹងលើពាក្យបញ្ចុះបញ្ចូលដ៏ប៉ិនប្រសប់របស់យើង ។

៨- ទោះបីទីបន្ទាល់របស់យើងសាមញ្ញក៏ដោយ ក៏ទីបន្ទាល់បែប
នោះអាចធ្វើអោយមនុស្សមានបាបបើកចិត្តទទួលជឿ ដោយ
សារយើង :

☐ អួតអំពីព្រះវិហារដ៏ល្អរបស់យើង ។

☐ បង្ហាញសេចក្តីស្រឡាញ់ ។

៩- សេចក្តីស្រឡាញ់ដោយការប្រព្រឹត្តល្អ និងពាក្យសំដីដែល
ផុសចេញពីចិត្តស្មោះត្រង់ នឹងប៉ះពាល់ចិត្តដែលរឹងចចេស
បំផុតរបស់មនុស្ស ។ ប៉ុន្តែ យើងត្រូវបញ្ជាក់ខ្លាំងអំពី :

☐ ជំនឿរបស់យើង និងរបៀបដែលជំនឿនោះ បានផ្លាស់
ប្តូរជីវិតរបស់យើង ។

សូមចាំថា អ្នកដែលមិនទាន់ជឿ ជាមនុស្សស្លាប់ក្នុងអំពើបាបខាង
ព្រលឹងវិញ្ញាណ ។ ដូច្នេះ អ្នកនោះមិនអាចរស់ឡើងវិញដោយខ្លួន
ឯងបានទេ ! ។

ជាទូទៅ ព្រះជាម្ចាស់បើកចិត្តអ្នកដែលមិនទាន់ជឿណាម្នាក់
ដោយសារជំនឿរបស់ :

☐ មនុស្សដែលគេមិនដែលស្គាល់ ។

☐ មិត្តភក្តិជិតស្និទ្ធ ឬ សាច់ញាតិ ។

ផ្សាយដំណឹងល្អ ដោយឫទ្ធានុភាព
របស់ព្រះវិញ្ញាណដ៏វិសុទ្ធ

ព្រះយេស៊ូគ្រីស្តមានព្រះបន្ទូលសន្យានៅក្នុង កិច្ចការ ១:៨ ថា÷
*«ប៉ុន្តែ អ្នករាល់គ្នានឹងទទួលឫទ្ធានុភាពមួយ គឺឫទ្ធានុភាពនៃព្រះ-
វិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើអ្នករាល់គ្នា ។ អ្នករាល់គ្នានឹងធ្វើជា
ទីបន្ទាល់របស់ខ្ញុំនៅក្នុងក្រុងយេរូសាឡឹម ក្នុងស្រុកយូដាទាំងមូល
ក្នុងស្រុកសាម៉ារី និងរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី »* ។

ទ្ធានុភាពនេះ គឺសំរាប់អោយអ្នកជឿផ្សាយដំណឹងល្អ ។ យើងត្រូវឧស្សាហ៍អធិស្ឋានទូលសូមឱ្យព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណដ៏វិសុទ្ធដល់យើង ដើម្បីអោយយើងអាចផ្សាយដំណឹងល្អប្រកបដោយប្រសិទ្ធិភាពបាន ។ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងធ្វើអោយពាក្យសំដីមិនក្បោះក្បាយរបស់យើង ប៉ះពាល់ចិត្តមនុស្សយ៉ាងខ្លាំង ។



៤- យើងស្រួលនាំមិត្តភក្តិ និងសាច់ញាតិយើងមកថ្វាយព្រះ-គ្រីស្ត ជាងនាំពួកអ្នកដែលយើងមិនធ្លាប់ស្គាល់ ។ ប៉ុន្តែយើងត្រូវទុកចិត្តថា ព្រះអង្គនឹងធ្វើកិច្ចការក្នុងចិត្តគំនិតរបស់មនុស្ស តាមរយៈ :

☐ បុគ្គលិកលក្ខណៈរឹងមាំរបស់យើង ។

☐ ការផ្សាយដំណឹងល្អរបស់យើងថ្វាយព្រះគ្រីស្ត ។

៥- នៅពេលដែលយើងប្រាប់មនុស្សម្នាក់ ដែលបានកែប្រែចិត្តគំនិតពីអំពើបាបថា ព្រះគ្រីស្តលើកលែងទោសអោយគេ គឺយើងប្រើ :

☐ ក្លូនសោនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ។

☐ ប្រាជ្ញារបស់យើងក្នុងការបង្ហាញសេចក្តីពិត ។

៦- ក្លូនសោរបស់ដំណឹងល្អ បើកទ្វារសង្គ្រោះសំរាប់មនុស្សដែលមានបាប តាមរយៈបុទ្ធានុភាពរបស់ :

☐ ព្រះវិញ្ញាណដ៏វិសុទ្ធ ។

☐ អ្នកជឿដែលថ្វាយខ្លួនដាច់ដល់ព្រះអង្គ ។

© Project WorldReach © SEAN

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- កូនសោដែលមានប្រសិទ្ធិភាពជាងគេ សំរាប់ធ្វើឱ្យក្រុមជំនុំរីកចំរើន គឺ :

- ☐ ការទៅសួរសុខទុក្ខជាមួយអ្នកជឿឯទៀត ដើម្បីផ្សាយដំណឹងល្អ ។
- ☐ ការធ្វើកម្មវិធីថ្វាយបង្គំ ។

២- របៀបប្រសើរបំផុត សំរាប់បង្រៀនពួកអ្នកជឿថ្មីអោយផ្សាយដំណឹងល្អ គឺ :

- ☐ សិក្សាសៀវភៅជាច្រើនអំពីការផ្សាយដំណឹងល្អ ។
- ☐ ធ្វើជាគំរូក្នុងការផ្សាយដំណឹងល្អដល់គេ ។

៣- ពួកអ្នកជឿថ្មីត្រូវធ្វើតាមគំរូគ្រូបង្ហាត់របស់គេ ។ ដំបូងយើងត្រូវផ្សាយដំណឹងល្អប្រាប់ :

- ☐ ពួកអ្នកមិនធ្លាប់ស្គាល់ ។
- ☐ មិត្តភក្តិ និងសាច់ញាតិ ។



© Project WorldReach © SEAN

យើងផ្សព្វផ្សាយដំណឹងល្អអំពីព្រះគ្រីស្ត ដោយអំណាចរបស់ព្រះជាម្ចាស់ដ៏ខ្ពស់បំផុត ។ បើសិនជាប្អូនថ្វាយសិរីល្អទៅព្រះយេស៊ូនោះ ទោះបីពាក្យសំដីប្អូនមិនក្បោះក្បាយក៏ដោយ ក៏ប្អូនអាចបន្ធូរចិត្តរឹងចចេសរបស់គេបានដែរ (យេរេមី ២៣:២៩) ។



ខ្ញុំដឹងហើយ បងជីដូនមួយរបស់ខ្ញុំឈ្មោះចាន់ បាននាំខ្ញុំនិងក្រុមគ្រួសាររបស់គាត់ឲ្យជឿលើព្រះគ្រីស្ត ។ តែគាត់មិនចេះនិយាយពីរោះក្បោះក្បាយប៉ុន្មានទេ ! គាត់ថែមទាំងបាក់អស់ធ្មេញមុខខ្លះទៀតផង ! ប៉ុន្តែ គាត់បាននាំឲ្យខ្ញុំព្រមទទួលថា ខ្ញុំជាមនុស្សឃោរឃៅ ដែលត្រូវការអោយព្រះយេស៊ូគ្រីស្តលើកលែងទោសអោយខ្ញុំ ។

សារឿនបានរៀនពីរបៀបផ្សាយដំណឹងល្អ ដោយមើលគំរូរបស់លោកគ្រូគង្វាលគាត់ ។ បន្ទាប់មក សារឿននាំឪពុកគាត់ទៅផ្សាយដំណឹងល្អប្រាប់មិត្តភក្តិរបស់គេទាំងពីរនាក់ទៀត ។

នៅពេលដែលអ្នកណាម្នាក់ទទួលព្រះគ្រីស្តហើយ យើងត្រូវបង្រៀនអ្នកនោះអោយចេះផ្សាយដំណឹងល្អដោយខ្លួនឯង ។ យើងក៏បង្រៀនអ្នកនោះអោយចេះប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ថែមទៀតផង ។

ខ្ញុំមកនិយាយអំពីដំណឹងល្អប្រាប់ឯងណា ។



ល្អណាស់ ! ខ្ញុំចង់ដឹងថា អ្វីដែលធ្វើអោយឯងផ្លាស់ប្តូរដូចនេះ ។ ឯងឈប់ស្រវឹង ហើយឈប់ទាស់ទែងជាមួយអ្នកជិតខាងទៀត ។

ផ្សាយដំណឹងល្អ ដើម្បីបង្កើតសាវ័កស្មោះត្រង់ថ្វាយព្រះគ្រីស្ត

យើងត្រូវធ្វើឱ្យពួកអ្នកជឿថ្មីជឿជាក់ថា គេបានសង្គ្រោះអស់កល្ប ហើយ (១ យ៉ូហាន ៥:១៣) និងត្រូវបង្រៀនពួកគេអោយចេះប្រតិបត្តិតាមសេចក្តីគ្រប់យ៉ាងដែលព្រះគ្រីស្តបានបង្គាប់ (ម៉ាថាយ ២៨:១៨-២០) ។







មានតែព្រះជាម្ចាស់ទេ ដែលអាចលើកលែងទោសអំពើបាប ។ ប៉ុន្តែ នៅពេលដែលមនុស្សមានបាបបានកែប្រែចិត្តគំនិត យើងត្រូវប្រកាសថា ព្រះជាម្ចាស់លើកលែងទោសឱ្យអ្នកនោះហើយ ។ នេះជារបៀបប្រើកូនសោរបស់ព្រះរាជ្យ (ម៉ាថាយ ១៦:១៩, ១៨:១៨) ។

ព្រះជាម្ចាស់សន្យាប្រទានកូនសោទាំងនេះដល់លោកពេត្រុសមុនគេ រួចប្រទានអោយពួកសាវ័កឯទៀតដែរ ។

- សូមប្រៀបធៀប ម៉ាថាយ ១៦:១៥-១៩ ជាមួយនឹង ម៉ាថាយ ១៨:១៨ និង យ៉ូហាន ២០:២២-២៣ ។
- ព្រះជាម្ចាស់ប្រទានទ្វានុភាពដូចគ្នានេះដល់អស់អ្នកដែលផ្សាយដំណឹងល្អថ្វាយព្រះគ្រីស្ត (រ៉ូម ១:១៦, ២ ធីម៉ូថេ ២:២, ៤:៥) ។

អ្នកទាំងបីនាក់នោះ អធិស្ឋានជាមួយគ្នា ។ ឪពុករបស់សារ៉ើនថាតាមមួយឃ្លាម្តងៗ...



ការផ្សាយដំណឹងល្អរបស់យើងថ្វាយព្រះគ្រីស្ត នឹងមានប្រសិទ្ធិភាព បើសិនជាយើងនិយាយប្រាប់ដោយ :

☐ បន្ទឺសំឡេងខ្លាំងៗ ។

☐ សេចក្តីស្រឡាញ់ តាមរយៈការប្រព្រឹត្តអំពើល្អ ។

រៀបរាប់អំពីព្រះយេស៊ូគ្រីស្តច្រើនជាងគេ

(លូកា ២៤:៤៦-៤៨)

ព្រះវិញ្ញាណដ៏វិសុទ្ធជួយយើងផ្សាយដំណឹងល្អ ។ ខ្ញុំជឿថា ឪពុកខ្ញុំនឹងកែប្រែចិត្តគំនិត ។ ខ្ញុំនឹងនិយាយប្រាប់គាត់អំពីព្រះយេស៊ូ ។



ត្រូវហើយ យើងជាសាក្សីរបស់ព្រះយេស៊ូ ។ បើយើងគ្រាន់តែនិយាយអំពីជីវិតចាស់របស់យើងអាក្រក់យ៉ាងណាខ្លះ និង អំពីជីវិតថ្មីរបស់យើងសព្វថ្ងៃនេះល្អយ៉ាងណា នោះយើងមិនអាចនាំមនុស្សឯទៀតអោយទទួលជឿព្រះយេស៊ូទេ ។ យើងត្រូវនិយាយប្រាប់ឪពុកបួនអំពីព្រះគ្រីស្តដែលជាព្រះបុត្រារបស់ព្រះជាម្ចាស់ អំពីការអស្ចារ្យដែលព្រះអង្គធ្វើ សេចក្តីស្រឡាញ់របស់ព្រះអង្គ ការសុគតរបស់ព្រះអង្គដើម្បីលោះបាបយើង និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ ព្រមទាំងអំពីវត្តមានរបស់ព្រះអង្គក្នុងយើងផងដែរ ។

ពួកគ្រីស្តជន ប្រព្រឹត្តខុសប្លែកពីមនុស្សឯទៀត ។ ពេលខ្ញុំឈឺ មនុស្សមកពីក្រុមជំនុំរបស់លោកគ្រូបានមកជួយខ្ញុំ ។ មួយវិញទៀត មនុស្សពីក្រុមជំនុំរបស់លោកគ្រូសងបំណុលខ្ញុំ ដោយមិនបាច់ខ្ញុំទារ ។ ខ្ញុំក៏ចង់ក្លាយជាគ្រីស្តជនដែរ ។



អ្នកល្បើថ្មីម្នាក់នោះនិយាយជាមួយឪពុកគាត់...



សេចក្តីសំខាន់ដែលយើងត្រូវនិយាយ ពេលផ្សាយដំណឹងល្អ គឺអំពី :

☐ ការផ្លាស់ប្តូរក្នុងជីវិតយើង ។

☐ កិច្ចការដែលព្រះគ្រីស្តធ្វើ ដើម្បីជួយសង្គ្រោះយើង ។

យើងត្រូវធ្វើទីបន្ទាល់ថា ព្រះយេស៊ូសុគត និងរស់ឡើងវិញដើម្បីអោយយើងបានសង្គ្រោះ ។ ការផ្លាស់ប្តូរក្នុងជីវិតយើង ដែលជាលទ្ធផលនៃការសង្គ្រោះជាការសំខាន់មែន តែការប្រាប់ដំណឹងល្អអំពីព្រះគ្រីស្តជាការសំខាន់ជាង ។

ផ្សាយដំណឹងល្អ ដោយសេចក្តីស្រឡាញ់

បើយើងផ្សាយដំណឹងល្អ តែយើងមិនចេះស្រឡាញ់មនុស្សឯទៀតទេ នោះការផ្សាយដំណឹងល្អរបស់យើង គ្មានប្រយោជន៍អ្វីទាំងអស់ (១ កូរិនថូស ១៣:១) ។ សេចក្តីស្រឡាញ់ដោយការប្រព្រឹត្តល្អ ធ្វើអោយមនុស្សបើកចិត្តជឿដំណឹងល្អអំពីព្រះយេស៊ូ ។

១ យ៉ូហាន ៣:១៨ ចែងថា÷*«កូនចៅអើយ យើងមិនត្រូវស្រឡាញ់ត្រឹមតែបបូរមាត់ ឬ ពាក្យសំដីប៉ុណ្ណោះទេ គឺត្រូវស្រឡាញ់តាមអំពើដែលយើងប្រព្រឹត្ត និង តាមសេចក្តីពិតវិញ»* ។